វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី១០ ខែសីហា ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ការនាំចេញរបស់កម្ពុជាទៅអាមេរិច កើនឡើងដល់២៦%
- កំណើនប្រាក់ឈ្នួលនៅជប៉ុនដែលលឿនបំផុតក្នុងរយៈពេល២១ឆ្នាំនេះ
- អាមេរិចនឹងបង្កើនពន្ធគយលើទំនិញដែលនាំចូលពីចិនដែលមានតម្លៃស្មើ១៦ប៊ីលានដុល្លារអាមេរិច នៅថ្ងៃទី២៣ សីហា

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារ បណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធ របស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការនាំចេញរបស់កម្ពុជាទៅអាមេរិច កើនឡើងដល់២៦%

បើយោងតាមទិន្នន័យពាណិជ្ជកម្ម ចុងក្រោយរបស់រដ្ឋាភិបាលអាមេរិច ការនាំចេញទំនិញ និងសេវាកម្មរបស់កម្ពុជាទៅអាមេរិចមានចំនួន១.៧ ប៊ីលាន នៅក្នុង៦ខែដំបូង ដែលមានការកើនឡើងចំនួន២៦% បើធៀបនឹងកំឡុងពេលដូចគ្នាកាលពីឆ្នាំមុន។ ការនាំចេញពីអាមេរិចមកកម្ពុជាមានចំនួនតែ២១៤ លានដុល្លារអាមេរិច។

បើតាមសារព័ត៌មានភ្នំពេញប៉ុស្តិ៍ បានអោយដឹងថា ទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ឯកឧត្តម ម៉ី កល្យាណ បានលើកឡើងថា ការសម្រេចបានលទ្ធផលនេះ បានមកពីការពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសទាំង២ បើទោះបីជាមានភាពតានតឹងផ្នែកនយោបាយខ្លះនៅឆ្នាំមុនក៏ដោយ។

### គម្រោងរបស់កម្ពុជា និងថៃ ទៅលើប្រព័ន្ធទូទាត់ដោយយកកូដQRជាមូលដ្ឋាន

គម្រោងថ្មីមួយដើម្បីបង្កើតប្រព័ន្ធទូទាត់អេឡិចត្រូនិច ដោយយកកូដQRជាមូលដ្ឋានដែលបានប្រកាសនៅខែកក្កដា នឹងអាចឲ្យប្រជាជនខ្មែរ និងថៃ ធ្វើការទូទាត់នៅក្នុងប្រទេសដោយប្រើប្រាស់រូបិយវត្ថុរបស់ខ្លួន។ កម្ពុជាអាចប្រើប្រព័ន្ធកូដQR ដើម្បីធ្វើការទូទាត់ពីគណនីធនាគារដែលខ្លួនប្រើ ដោយមិនចាំបាច់ប្តូរប្រាក់ទៅជាប្រាក់បាតរបស់ថៃ នៅពេលដែលធ្វើដំណើរទៅប្រទេសថៃ។ គេរំពឹងថា វិធីសាស្ត្រនេះនឹងផ្តល់ប្រយោជន៍សម្រាប់ទេសចរណ៍ ឬការទូទាត់សម្រាប់ការព្យាបាលជាដើម។ សេវានេះមានគុណសម្បត្តិដូចជា មានភាពងាយស្រួល មានសុវត្ថិភាព និងមានតម្លៃទាប។

## តារាងប្រចាំសប្តាហ៍៖ ចំនួនប្រជាជនរៀបចំតាមអាយុ និងភេទ នៅក្នុងឆ្នាំ២០១៨

តារាងខាងក្រោមបង្ហាញពីពីរ៉ាមីតនៃចំនួនប្រជាជនកម្ពុជា រៀបចំតាមអាយុ និងភេទ នៅក្នុងឆ្នាំ២០១៨។ ចំនួនប្រជាជនសរុប ត្រូវបានប៉ាន់ស្មានប្រមាណ១៦,៣ លាន ដែលក្នុងនោះមានស្ត្រីចំនួន ៨,៤លាន ពោលគឺ៥១,២% និងបុរសចំនួន ៧,៩លាន គឺ ៤៨,៨%នេះបើយោងទៅតាមផ្នែកមួយរបស់អង្គការសហប្រជាជាតិទទួលបន្ទុកចំនួនប្រជាជន។

កម្ពុជាត្រូវបានមើលឃើញថា មានការកើនឡើងយ៉ាងឆាប់រហ័សសម្រាប់ប្រជាជននៅចន្លោះអាយុ១៥-៦៤ ដែលមានរហូតដល់ ១០,៥លាន (៦៤,២%នៃចំនួនប្រជាជនសរុប) ដែលចូលរួមយ៉ាងសំខាន់នៅក្នុងកំលាំងពលកម្មរបស់កម្ពុជា និងការរីកចម្រើននៃសេដ្ឋកិច្ច។




## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### កំណើនប្រាក់ឈ្នួល នៅក្នុងប្រទេសជប៉ុនលឿនបំផុតក្នុងរយៈពេល ២១ ឆ្នាំនេះ

ប្រាក់ឈ្នួលពិតនៅក្នុងប្រទេសជប៉ុន បានកើនឡើង២,៨ ភាគរយនៅខែមិថុនា ធៀបទៅនឹងខែមិថុនាឆ្នាំមុន ដែលនេះគឺជាកំណើនដ៏លឿនបំផុតក្នុងរយៈពេលជាង ២១ ឆ្នាំ។ ការកើនឡើងនេះគឺដោយសារដោយសារការកើនឡើងនូវប្រាក់រង្វាន់សម្រាប់រដូវក្តៅនេះបើយើងតាម The Japan Times.

ជាមួយគ្នាផងដែរ ការចំណាយរបស់គ្រួសារនៅក្នុងប្រទេសជប៉ុនធ្លាក់ចុះ ១,២ ភាគរយ បើទោះបីជាអ្នកប្រើប្រាស់ភេសជ្ជៈ ម៉ាស៊ីនត្រជាក់ និងការញ៉ាំអាហារខាងក្រៅ នៅក្នុងខែនៃរដូវក្តៅខ្លាំង។ បើទោះជាការចំណាយនៅក្នុងគ្រួសារមានការធ្លាក់ចុះ ដែលជាក្តីកង្វល់មួយ ការកើនឡើងនៅប្រាក់ឈ្នួលគួរតែ បានជួយដល់ធនាគារនៃប្រទេសជប៉ុននូវកិច្ចប្រឹងប្រែងរបស់ខ្លួនដើម្បីសម្រេចឲ្យបាននូវគោលដៅអតិផរណា ២ ភាគរយ។

ជាងនេះទៅទៀត រដ្ឋាភិបាលបានរាយការណ៍ថាគេសង្កេតឃើញមានសញ្ញានៃការចំណាយអាចនឹងកើនឡើងនៅក្នុងខែកក្កដា ដោយសារការចំណាយប្រាក់រង្វាន់កាលពីខែមិថុនា។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### សហរដ្ឋអាមេរិកបង្កើនពន្ធគយចំនួន ១៦ ប៊ីលានលើទំនិញរបស់ចិន នៅថ្ងៃ ២៣ ខែសីហា

សហរដ្ឋអាមេរិកនឹងដាក់ពន្ធគយ ២៥% ទៅលើទំនិញនាំចូលពីប្រទេសចិនចំនួន ២៧៩ មុខ ដែលមានទឹកប្រាក់សរុបចំនួន ១៦ ប៊ីលាន នៃទំនិញពាណិជ្ជកម្ម ដោយចាប់ផ្តើមពីថ្ងៃ ២៣ ខែសីហា ឆ្នាំ២០១៨។ ការិយាល័យតំណាងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកកាលពីថ្ងៃអង្គារកន្លងមកនេះ (រាយការណ៍ដោយBloomberg). នេះគឺជាលើកទី ២ តាំងពីខែកក្កដាមក សហរដ្ឋអាមេរិកបានដាក់ពន្ធគយលើទំនិញរបស់ចិន ធ្វើឲ្យមានការកើនឡើងនូវការតានតឹងនៃសង្គ្រាមពាណិជ្ជកម្ម រវាងប្រទេសមហាអំណាចសេដ្ឋកិច្ចទាំងពីរ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

សប្តាហ៍ក្រោយគឺការចេញផ្សាយនូវទិន្នន័យដែលមានភាពយឺតយ៉ាវ ដែលមានតែទិន្នន័យដូចការរំពឹងទុក - ជាពិសេសគឺកំណើន ផ.ស.ស នៅក្នុងប្រទេសសឹង្ហបុរី និងម៉ាឡេស៊ីសម្រាប់ត្រីមាសទី ២ ឆ្នាំ២០១៨។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និង ការអភិវឌ្ឍ ដែលក្រុម FACT នឹងចេញនូវសប្តាហ៍ក្រោយះ

ថ្ងៃច័ន្ទទី ១៣ ខែសីហា ឆ្នាំ ២០១៨

- ផ.ស.ស នៃប្រទេសសឹង្ហបុរីសំរាប់ត្រីមាសទី២ ឆ្នាំ ២០១៨
- ការវិនិយោគផ្ទាល់ពីបរទេសប្រទេសចិនខែកក្កដា

ថ្ងៃច័ន្ទទី ១៤ ខែសីហា ឆ្នាំ ២០១៨

- តម្លៃនាំចេញ នាំចូលនៃប្រទេសកូរ៉េសម្រាប់ខែកក្កដា
- ការលក់រាយនៃប្រទេសចិនសម្រាប់ខែកក្កដា
- ផលិតផលឧស្សាហកម្មនៃប្រទេសជប៉ុនសម្រាប់ខែមិថុនា

ថ្ងៃច័ន្ទទី ១៥ ខែសីហា ឆ្នាំ ២០១៨

- សន្ទស្សន៍តម្លៃនៃផ្ទះនៅប្រទេសចិនសំរាប់ខែកក្កដា

ថ្ងៃច័ន្ទទី ១៦ ខែសីហា ឆ្នាំ ២០១៨

- សមតុល្យពាណិជ្ជកម្មសំរាប់ខែកក្កដានៃប្រទេសជប៉ុន
- ការវិនិយោគសញ្ញាប័ណ្ណបរទេសនៃប្រទេសជប៉ុន ខែសីហា
- គណនីចរន្តនៃប្រទេសម៉ាឡេស៊ីសំរាប់ត្រីមាសទី២ ឆ្នាំ ២០១៨
- ផសសនៃប្រទេសម៉ាឡេស៊ីសំរាប់ត្រីមាសទី ២ ឆ្នាំ២០១៨

ថ្ងៃច័ន្ទទី ១៧ ខែសីហា ឆ្នាំ ២០១៨

- អត្រាអត់ការងារធ្វើនៅប្រទេសកូរ៉េសំរាប់ខែកក្កដា
- សមតុល្យពាណិជ្ជកម្មរបស់សឹង្ហបុរីសំរាប់ខែកក្កដា ។

************************